# កម្រងឯកសារវិនិយោគវិស័យវារីវប្បកម្ម

ខែមករា ២០១១

# មតិស្វាគមន៍ពី USAID

USAID មានសេចក្តីសោមនស្សរីករាយដើម្បីបង្ហាញជូនពី កម្រងឯកសារវិនិយោគការចិញ្ចឹមត្រីស្តីពីឧស្សាហកម្មវារីវប្បកម្មកម្ពុជា ។

វាជាធម្មតាទីផ្សារដាច់ស្រយាល ដែលព័ត៌មានទាក់ទងនឹងការវិនិយោគអាចមានការលំបាកទទួលបាន ។ ដូច្នេះ គោលបំណងនៃកម្រងឯកសារនេះដើម្បីជួយសន្សំការងារស៊ើបអង្កេតបឋមខ្លះៗរបស់ អ្នក និង ផ្តល់នូវចំណុចចាប់ផ្តើមដែលអ្នកអាចធ្វើការស៊ើបសួរព័ត៌មានកាន់តែលំអិត ។

ឯកសារនេះផ្តល់នូវទិដ្ឋភាពទំនោរដែលរំលេចចេញរូបរាងវិស័យចិញ្ចឹមត្រី និងកំណត់ពីកត្តាគន្លឹះដែលរួមចំណែកដល់ការរំពឹងទុកនៃការវិនិយោគប្រកបដោយសុវត្ថិភាព ។ ចំណោទបញ្ហាដែលនឹងត្រូវដោះស្រាយ មានដូចជា:

*តើកម្ពុជាមានធនធាន និងហេដ្ឋារចនាសម្ព័ន្ធចម្បង ដើម្បីគាំទ្រដល់ឧស្សាហកម្មវារីវប្បកម្មប្រកបដោយការប្រកួតប្រជែងដែរឬទេ?*

*តើស្ថានភាពទីផ្សារលើវិស័យជលផលយ៉ាងណា និង តើវាជះឥទ្ធិពលដល់វារីវប្បកម្មបែបណា?*

*តើរដ្ឋាភិបាលមានទស្សនៈបែបណា និងតើអ្នករំពឹងអាចទទួលបានការគាំទ្រអ្វីខ្លះ?*

*តើនរណាជាអង្គភាពពាក់ព័ន្ធសកម្មនៅក្នុងឧស្សាហកម្មវារីវប្បកម្ម តើអ្នកអាចទទួលព័ត៌មានបន្ថែមពីអ្នកណា?*

*តើឱកាសវិនិយោគឧស្សាហកម្មវារីវប្បកម្មសំខាន់នៅកន្លែងណា?*

កម្ពុជា ជាប្រទេសដែលមានសេដ្ឋកិច្ចរស់រវើកដែលទទួលបាននូវការកោតសរសើរយ៉ាងខ្លាំងចំពោះគោលនយោបាយវិនិយោគដោយមេត្រីភាព ។ កម្ពុជាបានបង្ហាញខ្លួនឯងផងដែរនូវសេដ្ឋកិច្ចរឹងមាំដែលបានងើបឡើងយ៉ាងឆាប់ពីវិបត្តិហិរញ្ញវត្ថុពិភពលោក ។ ធនាគារ ADB និង IMF ទាំងពីរបានលើកកម្ពស់ការព្យាករណ៍ពីកំណើន GDP សំរាប់កម្ពុជា ឆ្នាំ ២០១០ ដែលបង្ហាញពីដំណើរសេដ្ឋកិច្ចរឹងមាំ ។ ទន្ទឹមនោះ កម្ពុជាបានទទួលកំណើនសេដ្ឋកិច្ចយ៉ាងឆាប់

របស់នៅពេញមួយទសវត្សរ៍កន្លងមក នៅមានឪកាសវិនិយោគជាច្រើនបន្ថែមទៀតសំរាប់វិនិយោគិនជាសហគ្រិន ។ យើងសង្ឃឹមថា កម្រងឯកសារវិនិយោគវិស័យនេះ ដែលជំរុញឲ្យមានចំណង់ដល់ការវិនិយោគនៅក្នុងឧស្សាហកម្មវារីវប្បកម្ម និងសូមជូនពរ លោក លោកស្រី និងអាជីវកម្មរបស់លោក លោកស្រីឲ្យទទួលបានជោគជ័យ ។

សូមទទួលនូវការគោរពរាប់អានពី គម្រោង MSME Project, USAID

## ចំណុចខ្លាំងថ្នាក់ជាតិ

អស់រយៈពេលជាងមួយទសវត្សរ៍កន្លងទៅនេះ កម្ពុជាបានលេចឡើងជាប្រទេសមួយក្នុងតំបន់ដើរនាទីយ៉ាងរស់រវើកនិងរឹងមាំជាមួយនឹងកេតនភណ្ឌសំខាន់ជាច្រើនដែលចាំបាច់សំរាប់ការអភិវឌ្ឍន៍និងការអភិវឌ្ឍន៍អាជីវកម្មដោយជោគជ័យ ។

### បើកចំហចំពោះអាជីវកម្ម

- ✓ ពន្ធអាជីវកម្មទាប- ពន្ធ២០%លើផលចំណេញអាជីវកម្ម (អាចអនុគ្រោះពន្ធរហូតដល់៥ឆ្នាំ ចំពោះការខាតបង់ ។
- ✓ គ្មានការដាក់កំហិតលើម្ចាស់កម្មសិទ្ធិជាជនបរទេស ។
- ✓ ចំណាត់ថ្នាក់នាំមុខប្រទេសចិន ឥណ្ឌា វៀតណាមនិងឥណ្ឌូនេស៊ីចំពោះសេរីភាពសេដ្ឋកិច្ច[១]។
- ✓ ប្រព្រឹត្តិស្មើភាពចំពោះអ្នកវិនិយោគទាំងអស់ ។
- ✓ នាំមុខប្រទេសហ្វីលីពីន ចិន និងវៀតណាម ចំពោះការការពារអ្នកវិនិយោគ[២] ។
- ✓ គ្មានការត្រួតពិនិត្យតម្លៃលើទំនិញឬសេវាកម្ម។
- ✓ គ្មានការត្រួតពិនិត្យលើការប្តូររូបិយវត្ថុបរទេសឬគ្មានការដាក់កំហិតលើការប្តូរប្រាក់ ។
- ✓ គ្មានការដាក់កំហិតលើបរិមាណពាណិជ្ជកម្មបន្ថយរបាំងពន្ធគយ ។ កម្ពុជាទទួលបានការ អនុគ្រោះពន្ធគយ និងកូតាទៅកាន់ទីផ្សារធំៗរបស់ពិភពលោក(ដូចជា អាមេរិក អឺរ៉ុប ជប៉ុន និងប្រទេសជាសមាជិកអាស៊ានជាច្រើនទៀត) ។
- ✓ អាជ្ញាធរខេត្តមានសិទ្ធិអំណាចក្នុងការអនុម័ត ការវិនិយោគក្រោមទឹកប្រាក់២លានដុល្លារដើម្បីជំរុញការអភិវឌ្ឍន៍អាជីវកម្មឲ្យបានឆាប់រហ័ស ។

> *"កម្ពុជាកំពុងបើកចំហទាំងស្រុងចំពោះអាជីវកម្ម ហើយរាជរដ្ឋាភិបាលកម្ពុជានឹងខិតខំព្យាយាមអស់ពីសមត្ថភាពដើម្បីធានាបាននូវបរិយាកាសអនុគ្រោះ និងភាពជោគជ័យសម្រាប់រាល់សហគ្រាសទាំងអស់ នៅកម្ពុជា"* ប្រសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## កម្លាំងពលកម្មមានតម្លៃទាបនិងផលិតភាព

ដោយបៀបធៀបទៅនឹងអ្នកប្រកួតប្រជែងជាច្រើននៅក្នុងតំបន់ ប្រទេសកម្ពុជាមានអត្រាប្រាក់ឈ្នួលប្រកួតប្រជែង ហើយកម្លាំងពលកម្មមានផលិតភាពខ្ពស់ធ្វើឲ្យកម្ពុជាក្លាយជាទិសដៅដ៏ទាក់ទាញសម្រាប់ឧស្សាហកម្ម ដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ។

កាលពីប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ កម្លាំងពលកម្មកម្ពុជាបានកើនឡើងជាង៥០% ច្រើនជាងទ្វេរដងនៃអត្រាក្នុងប្រទេសផ្សេងៗរបស់អាស៊ាន[៣]។ដោយមានប្រជាពលរដ្ឋវ័យក្មេងច្រើន(ប្រជាពលរដ្ឋពាក់កណ្តាលមានអាយុក្រោម២០ឆ្នាំ)កម្លាំងពលកម្មនេះនឹងបន្តកើនឡើង ។

> *"ដូចជាប្រទេសចិន និងឥណ្ឌា នៅក្នុងសម័យកាលមុនៗដែរ កម្ពុជាត្រូវបានកំណត់ថា ជាកន្លែងដែល រំពឹងទុកនៅពេលអនាគតសម្រាប់ការវិនិយោគខាងការផលិត ជាពិសេស ដោយសារតែពលកម្មតម្លៃ ទាប និងបុព្វលាភហានិភ័យរបស់ប្រទេសទាប...កម្ពុជាក៏ទទួលបានអត្ថប្រយោជន៍ពីភាពស្ថិតនៅជិត ល្មមទៅនឹងឆ្នេរខាងលិចនៃសហរដ្ឋអាមេរិក"* ។
>
> - PriceWaterhouseCoopers, June 2008

## ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

កម្ពុជាមានទីតាំងល្អឥតខ្ចោះ នៅចំចំណុចកណ្តាលតំបន់ដែលមានឋាមពលបំផុតនៅក្នុងពិភពលោក។ ដោយស្ថិតនៅជាប់ប្រទេសថៃ និងវៀតណាម កម្ពុជាគឺជាច្រករបៀងសេដ្ឋកិច្ចខាងត្បូង នៃមហាអនុតំបន់ទន្លេមេគង្គ លាតសន្ធឹងពីទីក្រុងហូជីមិញ ដល់ក្រុងបាងកក ។

ដោយសារតែទីតាំងយុទ្ធសាស្ត្របែបនេះ កម្ពុជាទទួលបានការគាំទ្រពីអន្តរជាតិគួរឲ្យកត់សំគាល់ នៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់ខ្លួន ដើម្បីជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេស និងជាមួយប្រទេសជិតខាង ។ ជាលទ្ធផលការធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសវៀតណាម និងថៃកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ។




> *"អ្នកមានទីក្រុងធំៗបំផុតពីរនៅអាស៊ីអមសងខាងអ្នក ។ អ្នកមានប្រជាជន១៥លាននាក់នៅទីក្រុងបាងកក និង៨លាននាក់នៅទីក្រុង ហូជី មិញ ហើយអ្វីៗនឹងកើតមានកាន់តែច្រើនឡើងៗ ចន្លោះទីក្រុងទាំងពីរ" ។* - Edward Hopkins, CB Richard Ellis Group Inc.

## ហេតុផលវិនិយោគទុនលើវារីវប្បកម្មកម្ពុជា

### ១.សេចក្តីផ្តើម

នៅក្នុងសមាមាត្រទៅនឹងទំហំ កម្ពុជាមានជលផលទឹកសាបយ៉ាងធំបំផុតនៅលើពិភពលោក។ លើសពីនេះទៀត កម្ពុជាមានឆ្នេរសមុទ្រប្រវែង ៤៤០គមនៅតាមឈូងសមុទ្រថៃ។

ហេតុដូចនេះ វិស័យជលផលចូលរួមយ៉ាងធំធេងដល់ការងារ សន្តិសុខស្បៀង និងសេដ្ឋកិច្ចរបស់ប្រទេស។ ការប្រមូលផល ការកែច្នៃ និងពាណិជ្ជកម្មត្រូវបានប៉ាន់ស្មានប្រហែល៨-១២%នៃGDP កម្ពុជា។

ការចាប់ត្រីធម្មជាតិជានិច្ចកាលបានផ្តត់ផ្គង់ភាគច្រើនដល់ការបរិភោគត្រី ដោយសារតែភាពសំបូរត្រីនៅក្នុងធនធានធម្មជាតិ តែដោយហេតុនេះហើយបានជាកម្ពុជាមានកំរិតវារីវប្បកម្មទាប បើប្រៀបធៀបទៅនឹងប្រទេសអាស៊ានជិតខាងរបស់ខ្លួន ។

**ការផលិតវារីវប្បកម្ម និងកំណើន (២000-២00៨) ប្រៀបធៀបទៅនឹង អាស៊ាន[១២]**




តែទោះយ៉ាងណាក៏ដោយ នៅក្នុងឆ្នាំថ្មីៗនេះមានការផ្លាស់ប្តូរនូវការចាប់អារម្មណ៍ចំពោះវារីវប្បកម្មដែលជាដំណោះស្រាយសំរាប់ការផ្គត់ផ្គង់ដែលមានឧបសគ្គនៃចំនួនស្តុកដែលកើតឡើងជាធម្មតា និងប្រភពនៃប្រាក់ចំណូលនាំចេញ ។ មូលដ្ឋានវារីវប្បកម្មទាបទាក់ទងទៅនឹងប្រទេសជិតខាងអាស៊ាន ពីព្រោះធនធានធម្មជាតិដ៏សំបូរផ្តល់ករណីវិនិយោគរឹងមាំ ហើយនេះកំពុងធ្វើការជំរុញការអភិវឌ្ឍន៍នៅក្នុងវិស័យនេះ ។

## ២. ធនធាន

ទឹក ដី និងគ្រឿងផ្សំចំណីត្រី គឺមានសារៈសំខាន់ដើម្បីឲ្យឧស្សាហកម្មវារីវប្បកម្មមួយទទួលជោគជ័យ ។ កម្ពុជាសំបូរនូវធនធានទាំងនេះ ។

# ធនធានទឹកសាប

ទន្លេមេគង្គហូរកាត់ត្រង់ចំណុចកណ្តាលនៃប្រទេសកម្ពុជា ។ ប្រហែល៨៦%នៃទឹកដីកម្ពុជាគឺមានរួមទាំងអាងទន្លេមេគង្គ ដែលមានផ្លូវទឹក១៩%ហូរសំដៅត្រង់ទៅឈូងសមុទ្រថៃ។ជាង៣០%នៃប្រទេសកម្ពុជាគ្របដណ្តប់ដោយដីសើមជាប្រចាំ ឬតាមរដូវ ហើយបឹងធំ(ដែលគេស្គាល់ថា ជាបឹងទន្លេសាប) មានផ្ទៃទឹកខុសគ្នារវាង៣.០០០គម$^{២}$ និង ១៦.០០០គម$^2$ ដោយយោងតាមរដូវ គឺមានទំហំផ្ទៃទឹកសាបធំជាងគេបំផុតនៅក្នុងតំបន់ ។

ដោយសារប្រព័ន្ធទឹកស្ទឹង ទន្លេ និងបឹងធំល្វឹងល្វើយ ហេតុដូចនេះ បានជាវារីវប្បកម្មទឹកសាបជានិច្ចកាលមានច្រើនជាងវារីវប្បកម្មសមុទ្រ ។

វារីវប្បកម្មសមុទ្រ និងទឹកសាប ២០០៩[៦]

| វារីវប្បកម្ម | សរុប(តោន) | % |
|---|---|---|
| ទឹកសាប | ៤៧៩៤០ | ៩៦ |
| សមុទ្រ | ១៩០៥ | ៤ |
| សរុប | ៤៩៨៤៥ | ១០០ |

ជាប្រវត្តិសាស្ត្រ វិធីសាស្ត្រប្រើសំង និងបែរត្រូវបានគេអនុវត្តនៅលើបឹងទន្លេសាប និងតំបន់ជុំវិញបឹងទន្លេសាបដែលមានភាគច្រើនវារីវប្បកម្មទឹកសាប ។ តែទោះជាយ៉ាងណាក៏ដោយ គេអាចមើលឃើញតាមក្រាហ្វិកខាងក្រោម ការចិញ្ចឹមបានហូរមកដល់ភ្នំពេញ ដែលជារាជធានីរបស់កម្ពុជា និងជាទីផ្សារក្នុងប្រទេសធំបំផុតតែមួយគត់ ។ ៤០ភាគរយនៃវារីវប្បកម្មទឹកសាបទាំងមូលគឺបច្ចុប្បន្នមានទីតាំងនៅភ្នំពេញ និងខេត្តកណ្តាល ទន្ទឹមនោះ៣៥%ទៀតគឺស្ថិតនៅខេត្ត៥ដែលនៅជាប់ ។ នៅក្នុងតំបន់ទាំងនេះ ការចិញ្ចឹមត្រីក្នុងត្រពាំង/ស្រះកំពុងតែនិយមកើនឡើង ។

ការចិញ្ចឹមជាវារីវប្បកម្មតាមខេត្ត (២០០៩)[៧]



## *តំបន់សមុទ្រ និងឆ្នេរសមុទ្រ*

ឆ្នេរសមុទ្រកម្ពុជាមានប្រវែង៤៣៥គមដោយមិនរាប់ចូលកោះ និងដែនទឹកដែលលាតសន្ធឹង២០គមក្រៅសមុទ្រ ។ ជាសរុប តំបន់សេដ្ឋកិច្ចដែលប្រកាសទាំងមូលគឺទំហំ ៥៥.៦០០គម$^{២}$ ។ មានព្រំប្រទល់ជាប់សមុទ្រមានខេត្តបួនគឺ ខេត្តកោះកុង កំពត កែប និង ព្រះសីហនុ ដែលជាទីតាំងកំពង់ផែទឹកជ្រៅរបស់កម្ពុជា ។

តាមដ្យាក្រាមខាងក្រោមបានបង្ហាញ ស្ទើរតែវារីវប្បកម្មសមុទ្រទាំងអស់នៅតាមឆ្នេរសមុទ្រគឺផ្តោតលើខេត្តព្រះសីហនុ និងកោះកុង ។

វារីវប្បកម្មសមុទ្រតាមខេត្ត (២០០៩)[៧]




ក្រៅពីការផលិតនៃវារីវប្បកម្មសមុទ្រសរុប គេធ្វើការបែងចែកតាមផលិតផលនៅក្នុងឆ្នាំ២០០៩ គឺ:

**ការចិញ្ចឹមក្នុងសមុទ្រតាមផលិតផល(២០០៩)[៩]**

| ផលិតផល | % |
|---|---|
| គ្រែងឈាម | ៣៧ |
| គ្រុំ | ៣៣ |
| ត្រីសមុទ្រ | ២៤ |
| ផ្សេងៗ | ៦ |

## ដី

មានដីដ៏សំបូរសំរាប់កសិដ្ឋានវារីវប្បកម្ម និងផលិតចំណីត្រី។ ដីសរុបនៅប្រទេសកម្ពុជាគឺ១៨,១ លានហិកតា ដែលគាំទ្រដល់ចំនួនដង់ស៊ីតេប្រជាជនត្រឹមតែ ៧៥នាក់ក្នុង ១គម[២] ។ នៅក្នុងនេះ ដីមានទំហំ២,៦១ លានហិកតា គ្របដណ្តប់ដោយដីស្រែ និង ៥៦៩.០០០ហិកតា ជាដីដាំដំណាំផ្សេងៗ[១០] ។ កំណើនការដាំដំណាំគឺជាគោលដៅគន្លឹះ សំរាប់រាជរដ្ឋាភិបាលកម្ពុជា ហើយដែលរដ្ឋាភិបាលស្វែងរកការដាំដំណាំនេះតាមរយៈដីសម្បទាន ។

## ពលកម្ម

កម្ពុជាមិនត្រឹមតែគេទទួលស្គាល់ជាអន្តរជាតិ ជាទីតាំងផ្តល់កម្លាំងពលកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានប្រវត្តិយូរលង់ណាស់មកហើយអំពីការកែច្នៃត្រីមានលក្ខណៈសិល្បៈផងដែរ ។ លើសពីនេះទៀត រដ្ឋបាលជលផល និងដៃគូអភិវឌ្ឍន៍នានា បានធ្វើការវិនិយោគយ៉ាងធំធេងក្នុងការបណ្តុះបណ្តាលដើម្បីធានានូវការចិញ្ចឹមក្នុងស្រុក និងការកែច្នៃដើម្បីបន្ថែមតម្លៃ។ ហេតុដូចនេះ កម្លាំងពលកម្មមានមូលដ្ឋានជំនាញចាំបាច់ ដែលវិនិយោគិនអាចខ្ចីទុន ។

# ៣. លក្ខខណ្ឌទីផ្សារ

លក្ខខណ្ឌទីផ្សារ គឺមានអំណោយផលខ្លាំងផងដែរក្នុងការពង្រីកវារីវប្បកម្ម ។ តម្រូវការក្នុងស្រុកខ្លាំងក្លានិងចេះតែកើនឡើង បង្ហាញនូវសក្តានុពលនាំចេញ និងការផ្គត់ផ្គង់រាំងស្ទះ គឺជាហេតុផលជំរុញដល់ការវិនិយោគ ។

## តម្រូវការក្នុងស្រុក

ការបរិភោគត្រី គឺមានច្រើនគិតជាមធ្យមភាគនៅលើពិភពលោក និងជាប្រភពដ៏ធំបំផុតនៃប្រូតេអ៊ីន (៨០)[១១] នៅក្នុងអាហារកម្ពុជា។ ប្រជាជនកម្ពុជាភាគច្រើនមិនរស់នៅឆ្ងាយពីរបនេសាទ ហេតុដូច្នេះហើយគេបរិភោគត្រីទឹកសាបជាចម្បង ។

តម្រូវការក្នុងស្រុកសំរាប់ផលិតផលសមុទ្រ រួមទាំងប្រភេទសត្វមានតម្លៃខ្ពស់តម្រូវការលើសលុបនៅទីក្រុងភ្នំពេញ ដែលគិតមាន១៥%នៃចំនួនប្រជាជនសរុប។ លើសពីនេះទៀត ទីក្រុងមានធនធានក្រាស់ក្រែលច្រើនជាងតំបន់ដទៃទៀតនៃប្រទេស និងមានសមាមាត្រអ្នកបរិភោគច្រើនបំផុត ។

ការប្រែប្រួលប្រជាសាស្ត្រសាស្ត្រ គឺកំពុងកើនឡើងនូវតម្រូវការត្រី ។ ការយកភ្នំពេញធ្វើជាតំណាងឲ្យប្រជាជនខ្មែរដែលសំបូរធនធានជាមធ្យម តារាងខាងក្រោមបង្ហាញពីកំណើននៃការបរិភោគត្រីសំរាប់ចំនួនប្រជាជនដែលធូរធា ។

**ត្រីនិងអាហារសមុទ្រស្រូបចូលក្នុងខ្លួនគិតជា%កាឡូរី (២០០៤)[១២]**




កំណើនប្រជាជនប្រចាំឆ្នាំ ១,៥៤% (២០០៨)[១៣] និងកំណើនជាប្រចាំក្នុងប្រាក់ចំណូលម្នាក់ៗត្រូវគេព្យាករណ៍កើនឡើងនូវតម្រូវការក្នុងស្រុកប្រហែលជា ១៥០.០០០តោន នៅឆ្នាំ ២០១៩[១៤] ។

## សក្តានុពលនាំចេញខ្លាំងក្លា

ការអភិវឌ្ឍន៍ឧស្សាហកម្មវារីវប្បកម្មដែលសំដៅទៅរកការនាំចេញមានស្ថេរភាព ដែលអាចផ្តល់នូវផលត្រឡប់មកវិញនូវសេដ្ឋកិច្ចជាប្រចាំដល់ប្រទេស

ដែលមានផលប្រយោជន៍យ៉ាងធំធេងដល់រាជរដ្ឋាភិបាលកម្ពុជា ។

តម្រូវការនាំចេញសំរាប់ត្រីគឺមានភាពរឹងមាំ។ ការប្រើប្រាស់កំណត់ត្រានាំចេញរបស់ប្រទេសគោលដៅ មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) ដែលប៉ាន់ស្មានការនាំចេញត្រីសរុបចំនួន ១០០លានដុល្លារឆ្នាំ ២០០៦ ។

តែទោះបីយ៉ាងណាក៏ដោយ ការនាំចេញជាផ្លូវការជារឿយៗតំណាងនូវចំនួននេះ ប្រតិបត្តិការជាច្រើនមិនបានកត់ត្រាជាផ្លូវការ ។ ទន្ទឹមនោះ ការនាំចេញជាផ្លូវការទាបអាចឆ្លុះបញ្ចាំងពីបញ្ហាសន្តិសុខស្បៀងក្នុងស្រុកផងដែរ ច្រើនជាងតម្រូវការនាំចេញពីព្រោះរដ្ឋាភិបាលជួនកាលកំហិតនូវការនាំចេញដើម្បីធានាមានស្បៀងអាហារគ្រប់គ្រាន់សំរាប់ប្រជាជនកម្ពុជារបស់ខ្លួន[១៥]។តារាងខាងក្រោមបង្ហាញនូវកំណើនតិចតួចនៅក្នុងការនាំចូលនៅក្នុងឆ្នាំថ្មី ដែលជំរុញជាចម្បងដោយផលិតផលសមុទ្រ[១៦] ។

**ការនាំចេញវារីវប្បកម្មកម្ពុជាជាផ្លូវការ (រាប់ពាន់តោន)[១៧]**




តាមក្រាហ្វិកមុន គេមើលឃើញផងដែរថាផលិតផលសមុទ្រគឺមានសមាមាត្រនាំចេញច្រើនខ្លាំង ដែលជាផលិតផលជលផលក្នុងស្រុកសរុប ។ នេះឆ្លុះបញ្ចាំងមិនត្រឹមតែតម្លៃការនាំចេញនូវផលិតផលសមុទ្រខ្ពស់ប៉ុណ្ណោះទេ តែប្រជាជនខ្មែរតាមទំនៀមទំលាប់និយមចូលចិត្តត្រីទឹកសាប ។

បច្ចុប្បន្ន ទីផ្សារនាំចេញធំសំរាប់ផលិតផលជលផលកម្ពុជា គឺប្រទេសអូស្ត្រាលី វៀតណាម ថៃ ចិន ម៉ាឡេ សិង្ហបូរី ហុងកុង និងកូរ៉េខាងត្បូង[១៨] ។

## ការផ្គត់ផ្គង់រាំងស្ទះ

ដូចដែលបានរៀបរាប់ពីមុនមក វារីវប្បកម្មនៅមានកំរិតដែលមានភាគរយតិចតួចនៃផលិតផលសរុប ដោយសារតែជលផលធម្មជាតិសំបូរ។ តែទោះយ៉ាងណាក៏ដោយ កត្តាប្រជាសាស្ត្រ និងបរិស្ថាន គឺកំពុងដាក់សំពាធកំណើនលើធនធានធម្មជាតិទាំងនេះ ដែលបង្កកំរិតការផលិតដោយនិរន្តរភាពធ្លាក់ទាបជាងតម្រូវការ។ ការធ្លាក់ចុះនេះមានបង្ហាញនៅតាមតារាងដូចខាងក្រោម ។

**គោលដៅចិញ្ចឹម ២០០៩-២០១០ (រាប់ពាន់តោន[១៩])**




ការឆ្លើយតបនិងការលើសពីតម្រូវការក្នុងស្រុកដើម្បីបង្កើនប្រាក់ចំណូលនាំចេញគឺជាអាទិភាពមួយសំរាប់រាជរដ្ឋាភិបាលកម្ពុជា ។ យុទ្ធសាស្ត្របានរៀបចំនៅក្នុងក្របខណ្ឌផែនការយុទ្ធសាស្ត្រសំរាប់ជលផល ២០១០-២០១៩ ដែលតម្រូវនូវការកំណត់ការចាប់ត្រីធម្មជាតិត្រឹម ៥០០ ០០០ តោន ក្នុងមួយឆ្នាំ ។ នេះតម្រូវនូវកំណើនទិន្នផលពីមួយឆ្នាំទៅមួយឆ្នាំ១៥% ទាំងវារីវប្បកម្មនិងការចិញ្ចឹមនៅតាមវាលស្រែ។ចំនួនលើសពីការហូបចុកនៅក្នុងស្រុកនឹងត្រូវប្រើសំរាប់ការនាំចេញ ។

ការរៀបចំស្ថាប័នអាចកំណត់នូវការផ្គត់ផ្គង់ផងដែរ ។ ត្រីឆ្តោជាប្រភេទត្រីដែលគេនិយមបរិភោគនៅទូទាំងអាស៊ី ចំនួនប្រជាជនសិង្ហបូរី៤.៥ លាននាក់បរិភោគចំនួន ១០០០តោនជាប្រចាំឆ្នាំ ។ តែទោះជាយ៉ាងណាក៏ដោយ ការចិញ្ចឹមត្រីដែលស៊ីសាច់ត្រីជាអាហារត្រូវបានហាមឃាត់នៅកម្ពុជាចាប់តាំងពីឆ្នាំ ២០០៤ ដោយសារផលប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរលើបរិមាណត្រី។ ជាធម្មតាត្រីឆ្តោស៊ីត្រី៥គកដើម្បីបានទំងន់ខ្លួនវាមួយគីឡូក្រាម ។

## ៤. បរិយាកាសលើកកម្ពស់អាជីវកម្ម

គន្លឹះដើម្បីសម្រេចបាននូវការពង្រីកវារីវប្បកម្មតាមការតម្រូវ គឺគេអនុម័តនូវបច្ចេកទេសថ្មី ជញ្ជីង

សេដ្ឋកិច្ច និងការលើកកម្ពស់ថ្នាំនិងចំណី។ នៅក្នុងផ្នែកទាំងនេះ រដ្ឋាភិបាលព្យាករណ៍នូវតួនាទីសំខាន់សំរាប់វិស័យឯកជន ដែលរដ្ឋាភិបាលស្វែងរកការលើកទឹកចិត្តតាមរយៈការរួមផ្តុំគោលនយោបាយលើកកម្ពស់ ការវិនិយោគសាធារណៈ និងរង្វាន់លើកទឹកចិត្តវិនិយោគ ។

## គោលនយោបាយគាំទ្រ

នៅក្នុងផែនការយុទ្ធសាស្ត្រជាតិបច្ចុប្បន្ន រដ្ឋាភិបាលបានកំណត់នូវវារីវប្បកម្មនៅឆ្ងាយពីសមុទ្រ និងឆ្នេរសមុទ្រ ការកែច្នៃនិងវេចខ្ចប់ត្រី ជាផ្នែកដ៏សំខាន់ដែលជួយលើកទឹកចិត្តដល់ការវិនិយោគ និងការអភិវឌ្ឍន៍ ។ នេះតាមការបង្ហាញនៅក្នុងក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់ រដ្ឋបាលជលផលសំរាប់ ជលផល ២០១០- ២០១៩ ដែលបានកំណត់នូវគោលដៅសំរាប់ការចិញ្ចឹមជាវារីវប្បកម្មនិងការនាំចេញដូចខាងក្រោម ។

គោលដៅឧស្សាហកម្មវារីវប្បកម្ម[២០]

| ការផ្តោត | ការសិក្សា២០០៨ | គោលដៅ២០១៩ |
|---|---|---|
| ទិន្នផលវារីវប្បកម្ម | ៤០ ០០០តោន | ប្រចាំឆ្នាំ ១៨៥ ០០០តោន |
| ការចិញ្ចឹមត្រី | ៤៤០០០នាក់ | អ្នកចិញ្ចឹម ៨៥ ០០០នាក់ |
| ការផលិតកូនត្រីពូជ | ៣៧លាន | ប្រចាំឆ្នាំ២៥០លានលាន |
| ការផលិតចំណីត្រី | មិនទាន់មាន | កំណើនទិន្នផលបន្លែក្នុងស្រុកត្រឹម៦០%តាមការសិក្សា |

ដើម្បីសម្របសម្រួលការចូលទៅកាន់ទីផ្សារ រដ្ឋបាលជលផល កំពុងរៀបចំក្របខណ្ឌស្តង់ដា និងនីតិវិធីអធិការកិច្ចដើម្បីធានាការចិញ្ចឹមក្នុងស្រុក ឲ្យស្របទៅតាមស្តង់ដាគុណភាពអន្តរជាតិ ។ នេះរួមបញ្ចូលទាំងការអនុវត្តន៍ការឃ្លាំមើល ការតាមដាន និងប្រព័ន្ធត្រួតពិនិត្យចំពោះការផ្ទុះជំងឺត្រីនៅចុងឆ្នាំ ២០១៤ ។

ជាការកំណត់នូវការប្តេជ្ញាចិត្ត ការកំណត់ថវិការបស់រដ្ឋបាលជលផលសំរាប់វារីវប្បកម្ម និងក្រោយការប្រមូលផល និងពាណិជ្ជកម្ម(ដែលគិតរួមទាំងការកែច្នៃ និងការនាំចេញ) គឺ ៥១% សំរាប់រយៈពេលផែនការយុទ្ធសាស្ត្រ ។

## រង្វាន់លើកទឹកចិត្តសំរាប់ការចាប់ផ្តើម

**គម្រោងវិនិយោគលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIPs)** ទទួលបានការអនុម័តដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ទទួលបានការលើកទឹកចិត្តហិរញ្ញវត្ថុមួយចំនួន តែមិនកំណត់ រួមមាន ការលើកលែងពន្ធថ្លៃឈប់សំរាក និងការរួចពន្ធនាំចូលសំរាប់ឧបករណ៍ផលិត និងសំភារៈសំណង់ និងទទួលបានការរួចពន្ធនាំចេញ១០០%ទៀតផង។ QIPs មិនតម្រូវធ្វើការបង់ថ្លៃមុននូវពន្ធប្រាក់ចំណេញ និងការដាក់ពន្ធអប្បបរមានៅអំឡុងពេលការរួចពន្ធ ។

ខាងក្រោមគឺជាច្រកសំរាប់ដាក់ពាក្យសុំលក្ខខណ្ឌ QIPs លើឧស្សាហកម្មវារីវប្បកម្មៈ

- ការផលិតចំណីសត្វដែលមានតម្លៃ២០០ ០០០ ដុល្លារអាមេរិក ឬលើសពីនេះ
- ការផលិតស្បៀងអាហារ ឬភេសជ្ជៈ ដែលមានតម្លៃ៥០០ ០០០ដុល្លារអាមេរិក ឬលើសពីនេះ
- ការបង្កក/ការកែច្នៃនូវផលិតផលវារីសត្វដើម្បីនាំចេញដែលមានតម្លៃ៥០០ ០០០ដុល្លារអាមេរិក ឬលើសពីនេះ។

ការវិនិយោគទុនក្រោមទឹកប្រាក់ ២លានដុល្លារ គឺត្រូវអនុម័តដោយខេត្ត ដោយមិនចាំបាច់ការអនុម័តយល់ព្រមពី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) នៅភ្នំពេញឡើយ ។ ខេត្តនីមួយៗ មាន អនុគណៈម្មាធិការវិនិយោគខេត្តសំរាប់គោលបំណងនេះ ដែលមានអភិបាលខេត្តជាប្រធាននិងជាតំណាងតំបន់របស់CDC។ កន្លែងណាដែលអនុគណៈកម្មាធិការមិនទាន់ដំណើរការពេញលេញទេ វិនិយោគិនអាចដំណើរការតាមរយៈ CDC នៅភ្នំពេញ ។

**តំបន់សេដ្ឋកិច្ចពិសេស** (SEZ)៖ តំបន់សេដ្ឋកិច្ចពិសេសអាចផ្តល់នូវលក្ខខណ្ឌអនុគ្រោះចំពោះការបង្កើតរោងចក្រនិងការកែច្នៃ។ដែលស្ថិតនៅតាមតំបន់ព្រំដែន និងក្បែរតំបន់ដែលប្រជាជនរស់នៅច្រើន គេទទួលផលពីហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ សេវាទឹក ភ្លើងថោក និងងាយស្រួលចូលទៅកាន់ទីផ្សារ ។

### តំបន់សេដ្ឋកិច្ចតាមខេត្តដែលទទួលបានការអនុញ្ញាត[២១]




រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តតំបន់សេដ្ឋកិច្ចពិសេសចំនួន២១ ។ ៦កន្លែង គឺកំពុងដំណើរការ និង ១៥កន្លែងទៀតនឹងដំណើរការសកម្មភាពនៅឆ្នាំ២០១៥[២២] ។

បន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ វិនិយោគិនតំបន់សេដ្ឋកិច្ចពិសេស ទទួលបានការរួចពន្ធនូវពន្ធបន្ថែមលើតម្លៃ(VAT)អំពីផលិតផលនិងសម្ភារៈនាំចូលផ្សេងៗនិងជាចំណុចតែមួយគត់នៃការទទួលបានសេវានានារបស់រដ្ឋាភិបាលៈ

### សេវាតំបន់សេដ្ឋកិច្ចពិសេស

| ច្រកចេញចូលតែមួយ | ហេដ្ឋារចនាសម្ព័ន្ធមានគុណភាព |
|---|---|
| ការចុះបញ្ជីវិនិយោគទុន<br>លិខិតអនុញ្ញាតនាំចូល/នាំចេញ<br>ទូទាត់បញ្ជីគយ<br>ការចាត់ចែងកម្លាំងពលកម្ម | អគ្គិសនី<br>ទឹកស្អាត<br>មានសេវាអ៊ិនធឺណេតជឿទុកចិត្ត |

អាជីវកម្មនៅក្នុង តំបន់សេដ្ឋកិច្ចពិសេស ក៏ទទួលបានផលពីរង្វាន់លើកទឹកចិត្តឆ្នាំសារពើពន្ធផងដែរ រួមទាំងពន្ធនាំចូល គយ និងផលប្រយោជន៍ VAT ។

### សេវាហិរញ្ញវត្ថុ

កម្ពុជាមានវិស័យហិរញ្ញវត្ថុរីកចម្រើន ដែលមានធនាគារ៣៣ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ២០ ដែលផ្តល់អាជ្ញាប័ណ្ណដោយ ធនាគារជាតិនៃ កម្ពុជា ។ ជារួមស្ថាប័នទាំងនេះផ្តល់ប្រាក់កម្ចីប្រហែល ៣០០០ លានដុល្លារអាមេរិកនៅឆ្នាំ២០០៩ ។ ធនាគារតាមអ៊ិនធឺណេត ធនាគារចល័ត និង ATMs ជាទូទៅ មាននៅក្នុងតំបន់ទីក្រុង និងទីប្រជុំខេត្ត ។ ដើម្បីជំរុញគុណភាពវិស័យនេះ ធនាគារជាតិនៃ កម្ពុជា បានតម្រូវឲ្យ ធនាគារពាណិជ្ជកម្មនីមួយៗបង្កើនដើមទុនតម្កល់គុណនឹងបីដង ប្រហែល ៣៧លាន[២៣]ដុល្លារអាមេរិក ចាប់មានប្រសិទ្ធភាពនៅចុងឆ្នាំ ២០១០។

## ៥. ហេដ្ឋារចនាសម្ព័ន្ធ

## ប្រព័ន្ធចែកចាយ

សមាមាត្រប្រជាជនខ្ពស់រស់នៅតំបន់ជនបទ និងនៅជិតជលផលទឹកសាប ដូចនេះ ពាណិជ្ជកម្មក្នុងស្រុកជាច្រើន គឺជាអនុតំបន់ អ្នកលក់រាយ ឬពាណិជ្ជករធុនតូចទិញផ្ទាល់ពីកន្លែងដាក់ និងផ្គត់ផ្គង់ទៅឲ្យអ្នកបរិភោគក្នុងស្រុក ។ ដូច្នេះប្រព័ន្ធចែកចាយមានសារៈសំខាន់ជាចម្បងធ្វើជាបណ្តាញផ្តល់ត្រីមកមជ្ឈមណ្ឌលទីក្រុង ដែលមជ្ឈមណ្ឌលសំខាន់បំផុតគឺទីក្រុងភ្នំពេញ ។

ប្រព័ន្ធចែកចាយជាតិនិងការនាំចេញ គឺត្រូវបានរៀបចំនូវជុំវិញតំបន់ស្នូលសំខាន់បី ខេត្តព្រះសីហនុនៅផ្នែកភាគខាងត្បូង ដែលជាត្រីទឹកប្រៃត្រូវបានគេនាំមកទីផ្សារ ខេត្តសៀមរាបនៅតំបន់ភាគខាងជើងនៃបឹងធំ ដែលជាជលផលដ៏សំខាន់ ហើយនិងទី ក្រុងភ្នំពេញ ដែលជាទីផ្សារក្នុងស្រុកដ៏ធំបំផុតនៅក្នុងប្រទេស ។

### មជ្ឈមណ្ឌលចែកចាយនៅកម្ពុជា

| ទីតាំង | កម្មសិទ្ធិ |
|---|---|
| ព្រះសីហនុ | ១៩កន្លែងកម្មសិទ្ធិឯកជន(៧ធំ) |
| សៀមរាប | ៩កន្លែងគ្រប់គ្រងដោយរដ្ឋ |
| ភ្នំពេញ | ៣កន្លែងគ្រប់គ្រងដោយរដ្ឋ |

ត្រីត្រូវបាននាំចេញផ្ទាល់ពីខេត្តសៀមរាប និងខេត្តព្រះសីហនុទាំងពីរ ដូចនេះមជ្ឈមណ្ឌលចែកចាយនៅភ្នំពេញគឺមានសារៈសំខាន់បំរើទីផ្សារក្នុងស្រុក ។ នៅក្នុងរាជធានី មានមជ្ឈមណ្ឌលចែកចាយដែលគ្រប់គ្រងដោយរដ្ឋចំនួនបី ដែលមានទីតាំងនៅខាងក្រៅទីក្រុង ដែលទទួលត្រី ហើយចែកចាយទៅតាមបណ្តាញលក់រាយក្នុងតំបន់ទីក្រុង ។

ត្រីសមុទ្រមកដល់ពីឆ្នេរសមុទ្រ ជាធម្មតាឆ្លងកាត់តាមមជ្ឈមណ្ឌលចែកចាយទាំងនេះ និងដឹកជញ្ជូនត្រង់ពី មជ្ឈមណ្ឌលដែលគ្រប់គ្រងដោយឯកជននៅតាមឆ្នេរសមុទ្រភាគខាងត្បូង មកឲ្យអ្នកលក់រាយនិងភោជនីយដ្ឋាននៅក្នុងទីក្រុង ។

**ផ្លូវចែកចាយត្រី**[២៤]




## ការភ្ញាស់កូនត្រី

រដ្ឋាភិបាលបានបង្កើតកន្លែងភ្ញាស់កូនត្រីសាធារណៈមួយចំនួនតូច តែវាកំពុងតែមានការគាំទ្រដែលចេះតែកើនឡើងដល់ការអភិវឌ្ឍន៍កន្លែងភ្ញាស់ត្រីឯកជនតាមរយៈការផ្តល់ជំនួយបច្ចេកទេស ។

**ការភ្ញាស់កូនត្រី និងការផលិតកូនត្រីពូជ**[២៥]




**មជ្ឈមណ្ឌលអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រ (MADeC)** គឺជាកន្លែងភ្ញាស់ត្រីទំនើបមួយដែលបច្ចុប្បន្នកំពុងកសាងនៅខេត្តព្រះសីហនុ។គម្រោង៧,៣លានដុល្លារនេះ ផ្តល់មូលនិធិដោយជប៉ុន ក្រោមគម្រោងជំនួយឥតសំណង ដែលមានគោលដៅផលិតកូនត្រីឲ្យបាន៤០០ ០០០ ដល់ ៥០០ ០០០ កូនត្រីក្នុងមួយឆ្នាំ ។

## ការដឹកជញ្ជូន

ការវិនិយោគដ៏សំខាន់លើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនបានលើកកម្ពស់នូវការចែកចាយទូទាំងប្រទេស និងសក្តានុពលនាំចេញ ដែលផ្តល់លទ្ធភាពដល់អាជីវករនៅកម្ពុជា វាយលុកចូលទៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ក្នុងស្រុក និងពិភពលោកដែលបង្កើតឡើង ។

**ផ្លូវថ្នល់:** គេអាចចូលមកកាន់ទីក្រុងភ្នំពេញបានតាមរយៈផ្លូវថ្នល់ជាតិដែលកសាងយ៉ាងល្អតភ្ជាប់ជាមួយនឹងបណ្តាលខេត្តទាំងអស់[២៦] ។ មានច្រកព្រំដែនអន្តរជាតិចំនួន៧ នៅទូទាំងប្រទេស ដែលមានផ្លូវចេញចូលដោយគ្មានការរអាក់រអួលទៅប្រទេសជិតខាង ថៃ ឡាវ វៀតណាម ។

**ទន្លេ:** ជារឿយៗ ទន្លេមេគង្គត្រូវបានគេប្រើដើម្បីដឹកជញ្ជូនទំនិញប្រើប្រាស់ (សំខាន់លើកសិផល) និងបានតភ្ជាប់ពីកម្ពុជាទៅនឹង ប្រទេសឡាវ និងវៀតណាម។

**ផ្លូវដែក:** រាជរដ្ឋាភិបាលកម្ពុជា កំពុងសហការជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី(ADB)និងដៃគូម្ចាស់ជំនួយនានាដើម្បីស្តារផ្លូវដែកជាតិ ។ ផ្លូវដែកធំៗចំនួនពីរខ្សែរត់កាត់ពី ប៉ោយ ប៉ែត (នៅតាមព្រំដែនភាគខាងលិចជាប់ជាមួយនឹងប្រទេសថៃ) មក ភ្នំពេញ និងមួយខ្សែទៀត តភ្ជាប់ពី កំពង់ផែព្រះសីហនុ មក សំរោង រត់កាត់តាមព្រំដែនភាគខាងត្បូងជាប់ជាមួយនឹងប្រទេសវៀតណាម។ការស្តារឡើងវិញនូវគម្រោងផ្លូវដែកទាំងពីរនេះនឹងត្រូវបញ្ចប់នៅឆ្នាំ ២០១៣[២៧] ។

ជាចុងក្រោយ ការពាក់ព័ន្ធយ៉ាងជាក់លាក់ទៅនឹងផលិតផលសមុទ្រ គឺ ច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង ពីបាងកក ប្រទេសថៃ មកកាន់ ទីក្រុងហូជីមិញ ប្រទេសវៀតណាម ដែលរត់តាមបណ្តោយឆ្នេរសមុទ្រកម្ពុជា ។

## កាលានុវត្តន៍ភាពពាណិជ្ជកម្ម

បង្កើនតម្រូវការ ការផ្គត់ផ្គង់រាំងស្ទះ និងការលើកកម្ពស់ធំធេងដល់បរិយាកាសនិងហេដ្ឋារចនាសម្ព័ន្ធវិនិយោគកម្ពុជាដែលផ្តល់នូវឱកាសវិនិយោគដ៏សំខាន់លើវិស័យវារីវប្បកម្ម និងឧស្សាហកម្មដែលទាក់ទង រួមមានៈ

**កសិដ្ឋានចិញ្ចឹមត្រីៈ** ទោះបីកំណើនកើនឡើង នៅពេលថ្មីៗក៏ដោយ ការសិក្សាស្រាវជ្រាវខ្លះបានលើកឡើងថា កសិដ្ឋានចិញ្ចឹមត្រី គឺនៅមានតិចជាង១០% នៃសក្តានុពលសរុប[២៨] ហេតុដូចនេះ បង្ហាញនូវឱកាសកំណើនយ៉ាងធំ។ បច្ចេកទេសបែបបុរាណបន្តនៅរីករាលដាល ដូច្នេះមានផលវិនិយោគសក្តានុពលយ៉ាងធំធេង ទាក់ទងទៅនឹងការលើកកម្ពស់ប្រតិបត្តិការ កំរិតសេដ្ឋកិច្ច និងការជ្រើសរើសការបង្កាត់ពូជ ។

**ការផលិតចំណីត្រីៈ** វារីវប្បកម្មនៅក្នុងស្រះតម្រូវនូវចំណីដែលមានគុណភាពខ្ពស់ដើម្បីពង្រីកទិន្នផល។នៅពេលបច្ចុប្បន្ន តម្រូវការនេះគឺមានការពេញចិត្តជាផ្នែកប៉ុណ្ណោះតាមការនាំចូល សោហ៊ុយចំណាយគឺមានការលំបាកស្តារត្រឡប់មកវិញនៅក្នុងតម្លៃទីផ្សារត្រី និងដូច្នេះ ការផលិតចំណីត្រីក្រៅផ្លូវការ គឺនៅតែជ្រោតជ្រាប ។ ដូច្នេះ ការនិយមវារីវប្បកម្មក្នុងស្រះ/ត្រពាំង ចេះតែកើន ឡើងដែលបានឈានដល់ឱកាសកើនឡើងសំរាប់ការផលិតចំណីត្រីមានគុណភាពនៅក្នុងស្រុក ដែលប្រើប្រាស់នៅវត្ថុធាតុដើមដែលមានស្រាប់យ៉ាងច្រើន ។

**ការផលិតកូនត្រីពូជៈ** ខណៈដែលមានកំណើនខ្លាំងនៅក្នុងការផលិតកូនត្រីពូជ កម្ពុជានៅតែតម្រូវនូវបណ្តាញទីផ្សារកូនត្រីពូជដែលមានការរៀបចំនិងយន្តការចែកចាយដើម្បីបំពេញតម្រូវការ[២៩] ។

**ការរក្សាទុកដោយក្លាសហ្សេៈ** លើកកម្ពស់ការរក្សាទុក និងទុកដាក់គឺមានសារៈសំខាន់ដើម្បីរក្សានូវតម្លៃ ទប់ស្កាត់នូវការខាតបង់ក្រោយប្រមូលផល និងពង្រីកការនាំចូលដើម្បីទៅដល់ទីផ្សារទទួលបានប្រាក់ចំណេញកាន់តែច្រើន ។ គេបានប៉ាន់ស្មាននៅឆ្នាំ ២០០៥ ថា ៧០%នៃការផលិតទឹកកកទាំងអស់នៅកម្ពុជាត្រូវបានគេប្រើសំរាប់រក្សាទុកត្រី[៣០] ។

**ការកែច្នៃៈ** ការកែច្នៃ និងការកែច្នៃឡើងវិញ គឺជាដំណើរការដែលស្រូបយកកម្លាំងពលកម្មយ៉ាងច្រើន។ កម្ពុជាមិនត្រឹមតែផ្តល់នូវកម្លាំងការងារដែលមានតម្លៃល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានប្រវត្តិយូរអង្វែងនូវជំនាញក្នុងការរៀបចំផលិតផលតាមទម្រង់ផ្សេងៗដូចជាត្រីប្រឡាក់អំបិល ត្រីងៀត និង ត្រីឆ្អើរសំរាប់ប្រើប្រាស់ក្នុងស្រុក ។ ការដំណើរការកែច្នៃទ្រង់ទ្រាយធំមួយ ចំនួនទៀតកំពុងធ្វើអាជីវកម្មលើផលប្រយោជន៍ ទាំងនេះដើម្បីបំរើទីផ្សារនាំចេញ។

## ដៃគូអភិវឌ្ឍន៍នៅក្នុងឧស្សាហកម្មវារីវប្បកម្ម

ដៃគូអភិវឌ្ឍន៍វារីវប្បកម្មមួយចំនួនកំពុងជួយអភិវឌ្ឍន៍ដល់វារីវប្បកម្មវិស័យឯកជន ។

**គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា(MSME) ឧបត្ថម្ភ ដោយ USAID** សម្របសម្រួលបច្ចេកទេស និង អាជីវកម្មដល់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមរាប់ពាន់នៅតាមតំបន់ជនបទកម្ពុជា ។ គម្រោង MSME បានធ្វើការជាមួយនឹង វារីវប្បកម្ម និងអាជីវករផលិតចំណី/ថ្នាំ ដើម្បីលើកកម្ពស់បច្ចេកទេសផលិតកម្ម ការគ្រប់គ្រងអាជីវកម្ម និងពង្រឹងការពិភាក្សារវាងរដ្ឋ-ផ្នែកឯកជន ។

គម្រោង MSME ក៏បានផ្តោតអារម្មណ៍លើការសម្របសម្រួលជំនួយបច្ចេកទេសដល់វិស័យផ្សេងៗ ៨ រួមមានៈ ជ្រូក ឡ-ឥដ្ឋ ទឹកស្អាត និងបង្គន់អនាម័យ ការអភិវឌ្ឍន៍ជំនាញដល់ឧស្សាហកម្មកាត់ដេរ ទឹកឃ្មុំ ជ័រទឹក អេកូទេសចរណ៍ និងផ្លែឈើគុណភាពខ្ពស់ ។

**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)** ទទួលខុសត្រូវ មជ្ឈមណ្ឌលអភិវឌ្ឍន៍វារី វប្បកម្មសមុទ្រ នៅទំនប់រលក ខេត្តព្រះសីហនុ។

**គណៈកម្មាធិការទន្លេមេគង្គ(MRC)** ជំរុញ និងសម្របសម្រួលការគ្រប់គ្រងប្រកបដោយចិរភាព និងការរៀបចំទឹក និងធនធានដែលពាក់ព័ន្ធដល់ផលប្រយោជន៍ទៅវិញទៅមកនៃប្រទេសទាំងពីរ និងសុខុមាលភាពរបស់ប្រជាជន ដែលអនុវត្តដោយកម្មវិធីយុទ្ធសាស្ត្រ និងសកម្មភាពការងារ

ផ្សេងៗ ព្រមទាំងផ្តល់នូវព័ត៌មានវិទ្យាសាស្ត្រ និងផ្តល់ប្រឹក្សាយោបល់អំពីគោលនយោបាយ។

**អង្គការ WorldFish** គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលធ្វើការដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈការលើកកម្ពស់ជលផល និងវារីវប្បកម្ម ។ ការិយាល័យរបស់ខ្លួនប្រចាំនៅមហាតំបន់ទន្លេមេគង្គ មានទីតាំងនៅទីក្រុងភ្នំពេញ ។

**ធនាគារពិភពលោក** គាំទ្រដល់គម្រោងដែលទាក់ទងនឹងជលផលលើផ្នែកជីវចម្រុះ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។

**មជ្ឈមណ្ឌលអភិវឌ្ឍន៍ជលផលអាស៊ីអាគ្នេយ៍** (SEAFDEC) ផ្តល់នូវការបណ្តុះបណ្តាល ការស្រាវជ្រាវ និងសេវាព័ត៌មាន ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍ធនធានជលផល ។ សេវារបស់ខ្លួនគ្របដណ្តប់ទៅលើផ្នែកឧបករណ៍បច្ចេកវិទ្យា ជលផលទូលំទូលាយ វិស្វកម្មសមុទ្រ ការសិក្សា ពីមូលដ្ឋាននេសាទ និងការវាយតម្លៃស្តុក បច្ចេកវិទ្យាក្រោយការប្រមូលផល ព្រមទាំងការអភិវឌ្ឍន៍និងលើកកម្ពស់បច្ចេកទេសវារីវប្បកម្ម។ កម្ពុជាជាសមាជិករបស់ SEAFDEC ។

**រដ្ឋបាលជលផល** (FiA) គឺទីភ្នាក់ងាររបស់រដ្ឋាភិបាល ដែលទទួលបន្ទុកលើការគ្រប់គ្រង និងការអភិវឌ្ឍន៍ជលផលនៅកម្ពុជា ។ វាជាសេនាធិការរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ត្រូវការស្វែងយល់បន្ថែមទៀតទេ?

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

www.cambodiainvestment.gov.kh

សភាពាណិជ្ជកម្មកម្ពុជា

www.ccc.org.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

www.maff.gov.kh

វិទ្យាស្ថានជាតិស្ថិតិ

www.nis.gov.kh

គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា **(MSME)**

www.cambodiamsme.org

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
http://www.jica.go.jp/cambodia/english/

គណៈកម្មាធិការទន្លេមេគង្គ(MRC)

http://www.mrcmekong.org/

អង្គការ WorldFish

http://www.worldfishcenter.org/

មជ្ឈមណ្ឌលអភិវឌ្ឍន៍ជលផលអាស៊ីអាគ្នេយ៍ (SEAFDEC):

http://www.seafdec.org/cms/index.php

## ស្ថិតិគន្លឹះ

### ស្ថិតិត្រីតាមការសំឡឹងមើល (២០០៩)[៣១]

| | |
|---|---|
| ផលិតសរុប | ៥១០.000 តោន |
| ត្រីចាប់ធម្មជាតិសរុប | ៤៦៥.០០០តោន |
| វារីវប្បកម្មសរុប | ៥០.០០០ តោន |
| វារីវប្បកម្មទឹកសាប | ៩៦% |
| វារីវប្បកម្មសមុទ្រ | ៤% |
| ការនាំចេញ(កំណត់ត្រា) | ៣០.០០០ តោន |

### កម្ពុជាតាមការសំឡឹងមើល[៣២]

| | |
|---|---|
| ទំហំផ្ទៃក្រឡា | ១៨១.០៣៥គម$^{២}$ |
| អាកាសធាតុ | ត្រូពិច |
| សីតុណ្ហភាពជាមធ្យម | ២៧$^{0}$C ឬ ៨0F |
| ចំនួនប្រជាជន | ១៣.៣៩៥.៦៨២(២០០៨) |
| អត្រាកំណើនប្រ/ជប្រចាំឆ្នាំ | ១,៥៤% |
| ភាសាផ្លូវការ | ខ្មែរ |
| ភាសាពាណិជ្ជកម្ម | ខ្មែរ និងអង់គ្លេស |
| សាសនា | ព្រះពុទ្ធ |
| ឆ្នេរសមុទ្រ | ៤៤០គម |

### អត្រាពន្ធកម្ពុជា[៣៣]

| | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | ២០% |
| | លើកទឹកចិត្ត | 0% ឬ ៩% |
| ពន្ធអប្បបរមា | | ១%នៃផលរបរ |
| ពន្ធកាត់ទុក | | ១៥% |
| ប្រាក់ចំណូលពីការជួលអចលនវត្ថុ | | ១០% |
| ការបង់ប្រាក់ឲ្យអនិវាសនជន | | ១៤% |
| ពន្ធលើប្រាក់បៀវត្សរ៍(រៀលក្នុងមួយខែ) | | |
| 0 - ៥០០.000 | | 0% |
| ៥០០.00១-១.២៥០.000 | | ៥% |
| ១.២៥០.000 - ៨.៥០០.០០០ | | ១០% |
| ៨.៥០០.០០១ - ១២.៥០០.០០០ | | ១៥% |
| ១២.៥០០.០០០+ | | ២០% |
| អនិវាសនជន | អត្រាថេរ | ២០% |
| ពន្ធបន្ថែមលើផលបន្ទាប់បន្សំ | | ២០% |
| ពន្ធបន្ថែមលើតំលៃ | | ១០% |
| | នាំចេញ | 0% |
| ពន្ធការផ្ទេរសិទ្ធិលើអចលនវត្ថុ | | ៤% |

### ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចកម្ពុជា[៤]

| កំណើន GDP(%) | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|
| កំណើននាំចេញ | ១៣.៣ | ១០.8 | ១០.២ | ៦.៧ | -២ | ៤.៤ |
| លើទំនិញតែប៉ុណ្ណោះ | ១២.៤ | ២៦.៩ | ១០.៧ | ១៥.២ | -១៧ | ៥ |
| %នាំចេញលើតែទំនិញ | ៤៧% | ៥០% | ៤៧% | ៤៦% | ៣៩% | 0.៣៧ |
| វិនិយោគផ្ទាល់ពីបរទេស(FDI)លានដុល្លារ | ៣៧៥ | ៤៧៥ | ៨៦៦ | ៧៩៦ | ៥១៥ | ៧២៥ |
| FDI (% of GDP) | ៦% | ៦% | ១០% | ៨% | ៥% | 0.0៧ |

### ការចំណាយអាជីវកម្ម[៥]

| ដី | តំលៃលក់(គិតជាម$^{២}$) |
|---|---|
| ភ្នំពេញ ដីពាណិជ្ជកម្ម | ៨០០-៥០០០ដុល្លារ |
| សៀមរាប ដីពាណិជ្ជកម្ម | ៣០០-៥០០ ដុល្លារ |
| ខេត្តព្រះសីហានុ ដីពាណិជ្ជកម្ម | ៣០០-១០០០ដុល្លារ |
| ដីអភិវឌ្ឍន៍ (គ្រប់ខេត្ត/ក្រុង) | ៣០-១២០ ដុល្លារ |

| កន្លែងការិយាល័យ | ជួល/ខែ (គិតជាម$^{២}$) |
|---|---|
| តំបន់ល្អ | ១០-១៥ ដុល្លារ |
| តំបន់លំដាប់ទី២ | ៧-១០ ដុល្លារ |

| ពន្ធគយលើអគ្គិសនីនៅភ្នំពេញ ពាណិជ្ជកម្ម និងឧស្សាហកម្ម | ពន្ធគយ ដុល្លារ/kWh (មធ្យមភាគ ២០០៩) |
|---|---|
| តូច (<៦.៧៥០kWh) | 0,១៨៦៣ ដុល្លារ |
| មធ្យម( ≥៦.៧៥០kWh តែតិចជាង១៣.៥០០kWh) | 0,១៧៨៣ដុល្លារ |
| ធំ ( ≥១៣.៥០០kWh) | 0,១៧៤២ដុល្លារ |
| តផ្ទាល់ទៅនឹង MV | 0,១៧០៣ដុល្លារ |

ការផ្គត់ផ្គង់ឧស្ម័នឧស្សាហកម្ម 0,៣២ដុល្លារ/គក

| តំលៃពលកម្ម | ប្រាក់ខែ(មួយខែ) |
|---|---|
| អ្នកចាត់ការជាន់ខ្ពស់ | ១០០០-១៥០០ដុល្លារ |
| អ្នកចាត់ការមធ្យម | ៥០០-១០០០ដុល្លារ |
| អ្នកចាត់ការចូលដំបូង | ២៤០-៤០០ ដុល្លារ |
| គណនេយ្យករ | ២៥០-៤០០ ដុល្លារ |
| លេខាធិការ | ១២០-១៥០ ដុល្លារ |
| ស្មៀនការិយាល័យ | ១០០-១២០ ដុល្លារ |
| អ្នកបើកបរ | ១០០-១២០ ដុល្លារ |
| អ្នកសំអាត | ៥០-៨០ ដុល្លារ |
| កម្មករ | ៥០-៨០ ដុល្លារ |
| ប្រាក់ឈ្នួលអប្បបរមាសំរាប់កម្មកររោងចក្រកាត់ដេរ | ៦០ ដុល្លារ |